# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ១
បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# រចនាសម្ព័ន្ធតុលាការកម្ពុជា


រៀបចំដោយៈ

-ឯកឧត្តម **សេង ឌីណា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអនុប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

## I-អំពីប្រវត្តិនៃការបង្កើតប្រព័ន្ធតុលាការរបស់កម្ពុជា

ប្រព័ន្ធតុលាការកម្ពុជានៅសម័យបុរាណ ទទួលឥទ្ធិពលពីច្បាប់ខ្មែរបុរាណ ដែលជាច្បាប់ផ្ទាល់មាត់ និងគ្រប់ដណ្តប់ដោយឥទ្ធិពលនៃសាសនា។ ព្រះមហាក្សត្រ ដែលជាតំណាងអាទិទេពមានអំណាចគ្រប់យ៉ាង រាប់ទាំងអំណាចធ្វើសវនាការដោះស្រាយរឿងក្តីគ្រប់ប្រភេទផង។ ព្រះមហាក្សត្រទ្រង់មានមន្ត្រីមួយរូបជាជំនួយក្នុងកិច្ចការយុត្តិធម៌គឺ **"ឧកញ៉ាយមរាជ"** ដែលចាត់ទុកដូចជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម័យបច្ចុប្បន្ន។

នៅក្រោយពេលដែលបារាំងបានមកដាក់អាណាព្យាបាលលើកម្ពុជា កាលពីឆ្នាំ១៨៦៣ ប្រព័ន្ធតុលាការកម្ពុជាដែលធ្លាប់មានកន្លងមកនៅតែបន្តអនុវត្តសម្រាប់ដោះស្រាយវិវាទរវាងខ្មែរនិងខ្មែរ។ចំណែកវិវាទរវាងបរទេសនិងខ្មែរ ឬរវាងបរទេសនិងបរទេសត្រូវស្ថិតក្រោមយុត្តាធិការនៃប្រព័ន្ធតុលាការបែបបារាំង។ ក្រោយមកទៀត ប្រព័ន្ធតុលាការកម្ពុជាបុរាណក៏ត្រូវបានកែប្រែបន្តិចម្តងៗរហូតក្លាយជាប្រព័ន្ធតុលាការដែលយកតាមទម្រង់ដូចគ្នាទៅនឹងប្រព័ន្ធតុលាការបារាំង។

រចនាសម្ព័ន្ធតុលាការតាមបែបបារាំងនេះនៅតែបន្តអនុវត្តក្រោយពេលដែលកម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ រហូតមកដល់របបកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធតុលាការកម្ពុជានៅពេលនោះ ត្រូវបានបែងចែកជា សាលាលហុ (ឬ សាលាលុឃុន) និង សាលាដំបូង ដែលជាសាលាជម្រះក្តីជាន់ទាប ត្រូវបានបង្កើតឡើងនៅភ្នំពេញ និងនៅតាមបណ្តាខេត្តទូទាំងប្រទេស ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីដែលសាលាជម្រះក្តីនោះស្ថិតនៅនិងសាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ដែលមានតែនៅរាជធានីភ្នំពេញប៉ុណ្ណោះ និងមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីនៃប្រទេសកម្ពុជាទាំងមូល[1]។

នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអ្វីៗត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ដោយក្នុងនោះប្រព័ន្ធតុលាការក៏ត្រូវបានលុបបំបាត់ចោលផងដែរ។ រហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបប្រព័ន្ធតុលាការកម្ពុជាត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៨០ដោយក្រឹត្យច្បាប់លេខ ០១ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សារដ្ឋ ដោយគ្រានោះកម្ពុជា

1. សៀវភៅ "សង្គមវិជ្ជា", គីម សែត, ឆ្នាំ១៩៦០, ទំព័រទី៦៧ ដល់ ៨៤

បានបង្កើតឱ្យមាននូវ **"តុលាការប្រជាជនបដិវត្តខេត្ត-ក្រុង"** ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជា **"តុលាការប្រជាជនខេត្ត-ក្រុង និងអយ្យការអមតុលាការប្រជាជនខេត្ត-ក្រុង"** នៅឆ្នាំ ១៩៨២។ នៅពេលនោះ តុលាការកម្ពុជា គឺមានតែមួយថ្នាក់តែប៉ុណ្ណោះ។ បន្ទាប់មកនៅឆ្នាំ១៩៨៥ តុលាការកំពូល ដែលមានឈ្មោះ ថា **"តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល"** ត្រូវបានបង្កើតឡើងដោយក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥។ គិតមកទល់ពេលនោះកម្ពុជាមានតែតុលាការខេត្ត-ក្រុងនិងតុលាការកំពូលតែប៉ុណ្ណោះ ដោយពុំទាន់មានសាលាឧទ្ធរណ៍នោះទេ។ រហូតមកដល់ឆ្នាំ១៩៩២ ទើប **"សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍"** ត្រូវបានបង្កើតឡើង ដោយមានទីតាំងនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីទាំងមូលនៃរដ្ឋកម្ពុជា និងដោះស្រាយគ្រប់សំណុំរឿងទាំងអស់។ រចនាសម្ព័ន្ធតុលាការនេះ ត្រូវបានបន្តអនុវត្តរហូតដល់មានច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ និងព្រះរាជក្រឹត្យឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ចំនួន៣រួមមាន សាលាឧទ្ធរណ៍ព្រះសីហនុ សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងសាលាឧទ្ធរណ៍បាត់ដំបង បន្ថែមពីលើសាលាឧទ្ធរណ៍ភ្នំពេញដើម្បីបង្វិតសេវាយុត្តិធម៌ឱ្យកាន់តែខិតជិតប្រជាពលរដ្ឋនិងលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌នេះ ព្រមទាំងដើម្បីដោះស្រាយបញ្ហាកកស្ទះសំណុំរឿងដែលត្រូវប្រមូលផ្តុំនៅតែសាលា ឧទ្ធរណ៍ភ្នំពេញ។

## II-រចនាសម្ព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ន

ប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ និងត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើនៅថ្ងៃទី១៦ខែកក្កដាឆ្នាំ២០១៤។ យោងតាមច្បាប់នេះប្រព័ន្ធតុលាការកម្ពុជាត្រូវបានចែកចេញជា ២ ថ្នាក់ គឺ **តុលាការជាន់ទាប** (១) និង **តុលាការជាន់ខ្ពស់** (២) ហើយតុលាការទាំង ២ ថ្នាក់នេះអនុវត្តអំណាចតុលាការដែលគ្របដណ្តប់លើរឿងក្តីគ្រប់ប្រភេទរួមទាំងរឿងក្តីផ្នែករដ្ឋបាល [2] ផងដែរ។

## ១.តុលាការជាន់ទាប

តុលាការជាន់ទាបរួមមានសាលាដំបូងដែលត្រូវបានបង្កើតឱ្យមាននៅរាជធានីភ្នំពេញនិងនៅគ្រប់បណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា និងតុលាការយោធាដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលើគ្រប់រឿងក្តីទូទាំងប្រទេសពាក់ព័ន្ធនឹងបទល្មើសយោធា។

2. មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## ក-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

### (១)-សាលាដំបូង

សាលាដំបូង គឺជាសាលាជម្រះក្ដីទូទៅ ដែលមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីទាំងអស់ លើកលែងតែរឿងក្ដីដែលស្ថិតក្រោមសមត្ថកិច្ចនៃសាលាជម្រះក្ដីពិសេស ជាអាទិ៍ តុលាការយោធា ឬសាលាជម្រះក្ដីវិសាមញ្ញជាអាទិ៍អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានបង្កើតឡើងដោយច្បាប់ដោយឡែក[3]។ សាលាដំបូង ត្រូវបែងចែកជាតុលាការជំនាញ[4] ដែលរួមមាន **តុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី តុលាការពាណិជ្ជកម្ម និងតុលាការការងារ**។ តុលាការជំនាញផ្សេងទៀតរបស់សាលាដំបូង អាចត្រូវបានបង្កើតឡើងដោយយោងតាមសេចក្ដីត្រូវការចាំបាច់។ ការបង្កើត ការលុបចោល និងការកែប្រែតុលាការជំនាញ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ តុលាការជំនាញនីមួយៗរបស់សាលាដំបូងចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ។ ប៉ុន្តែដោយបច្ចុប្បន្នតុលាការជំនាញនៅមិនទាន់ត្រូវបានបង្កើតឡើង, ថៅក្រមនៃសាលាដំបូងរាជធានី-ខេត្ត មានសមត្ថកិច្ចលើរាល់រឿងក្ដីទាំងអស់។

សាលាដំបូងរាជធានី-ខេត្តនីមួយៗ មានសមត្ថកិច្ចជំនុំជម្រះគ្រប់រឿងក្ដី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្ដីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យសាលាជម្រះក្ដីផ្សេងទៀត។ ប៉ុន្តែ ក្នុងករណីចាំបាច់ដើម្បីធានានូវផលប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្ដីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន[5]។ ទន្ទឹមនេះ ដើម្បីធានាដំណើរការល្អនៃយុត្តិធម៌ សាលាដំបូងមួយក៏អាចផ្ទេរសមត្ថកិច្ចទៅអោយសាលាដំបូងមួយទៀតបានដែរ ដោយអនុវត្តស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀត។ ក្នុង ករណីមានវិវាទសមត្ថកិច្ចរវាងតុលាការជំនាញផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំតុលាការជំនាញដែលពាក់ព័ន្ធដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមសំណើរបស់ប្រធានតុលាការជំនាញណាមួយ ដើម្បីសម្រេចអំពីសមត្ថកិច្ច។ ប្រធានសាលាដំបូង សម្រេចលើវិវាទនេះដោយដីកាសម្រេច។ ដីកាសម្រេចនេះ គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។

3. មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
4. មាត្រា ៥ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
5. មាត្រា ១៩ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សមាសភាពរបស់សាលាដំបូងរាជធានី-ខេត្តនីមួយៗ រួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[6]។ ប្រធានសាលាដំបូងមានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានតុលាការជំនាញទាំងអស់នៃសាលាដំបូងនោះ។ ប្រធានតុលាការជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក។ ប្រធានសាលាដំបូង មិនអាចធ្វើជាប្រធានតុលាការជំនាញណាមួយបានឡើយ។ប្រធានតុលាការជំនាញនីមួយៗអាចធ្វើជាប្រធានតុលាការជំនាញបានតែមួយគត់នៃសាលាដំបូងនោះ។

ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី នៅសាលាដំបូង អាចធ្វើឡើងដោយចៅក្រមទោល ឬក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមទៅតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធីរដ្ឋប្បវេណីជាធរមាន[7]។

ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម នៅសាលាដំបូងត្រូវធ្វើឡើងដោយចៅក្រម៣រូបនិងអមដោយទីប្រឹក្សា ២រូប ជាពាណិជ្ជករ ឬជាអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម ក្នុងរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃចាប់ពី១ពាន់លានរៀលឡើងទៅ។ រឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃពី ១០០លានរៀល ដល់ក្រោម ១ពាន់លានរៀល ត្រូវជំនុំជម្រះដោយមានចៅក្រម ១រូប និងអមដោយទីប្រឹក្សាពាណិជ្ជកម្ម ២ រូប។ ចំណែករឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃក្រោមមួយរយលានរៀលត្រូវជំនុំជម្រះដោយចៅក្រម១រូបដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្ម។ ក្នុងករណីជំនុំជម្រះដោយមានទីប្រឹក្សាពាណិជ្ជកម្ម សាលក្រម ត្រូវសម្រេចដោយចៅក្រម ក្រោយពេលបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួនតាមការអញ្ជើញរបស់ប្រធានតុលាការពាណិជ្ជកម្មនៃសាលាដំបូង ហើយមិនបំពេញមុខងារជាអចិន្ត្រៃយ៍ឡើយ[8]។

ការជំនុំជម្រះរឿងក្តីការងារ នៅសាលាដំបូងត្រូវធ្វើឡើងដោយចៅក្រម១រូបនិងអមដោយទីប្រឹក្សាការងារ ២រូប ដែល ១រូប ជាកម្មករនិយោជិត និង ១រូបទៀតជានិយោជក។ សាលក្រមត្រូវសម្រេចដោយចៅក្រមក្រោយពេលបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ។ទីប្រឹក្សាការងារ ត្រូវចូលមកបំពេញមុខងាររបស់ខ្លួន តាមការអញ្ជើញរបស់ប្រធានតុលាការការងារនៃសាលាដំបូង ហើយមិនបំពេញមុខងារជាអចិន្ត្រៃយ៍ឡើយ[9]។

6. មាត្រា ១៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

7. មាត្រា ២០ កថាខណ្ឌទី២ និងមាត្រា ២១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

8. មាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

9. មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

នៅតាមសាលាដំបូងរាជធានី-ខេត្តនីមួយៗ ប្រធានសាលាដំបូងត្រូវចាត់តាំងឱ្យមានចៅក្រមស៊ើបសួរយ៉ាងតិច២រូប ដែលមានសមត្ថកិច្ចស៊ើបសួរក្នុងសំណុំរឿងព្រហ្មទណ្ឌ។ ការចាត់តាំងចៅក្រមស៊ើបសួរត្រូវធ្វើឡើងដោយដីកាសម្រេច ហើយនៅក្នុងដីកាសម្រេចត្រូវមានចែងកំណត់អំពីលំដាប់លេខរៀង សម្រាប់ការទទួលបំពេញការងារដោយចៅក្រមស៊ើបសួរនីមួយៗ[10]។

## (២)-អយ្យការអមសាលាដំបូង

នៅតាមសាលាដំបូងនីមួយៗ មានអយ្យការអមសាលាដំបូង ដែលមានសមាសភាព ដូចជាៈ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[11]។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានតែអង្គការអយ្យការទេដែលមានសិទ្ធិអំណាចផ្តាច់មុខក្នុងការធ្វើបណ្តឹងអាជ្ញា[12]។ អយ្យការមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន[13]។

អង្គការអយ្យការ គឺជាអង្គអវិភាគ។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងឱ្យអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំនិងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញា មានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញារងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានអំណាចចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារង ព្រមទាំងមានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានរបស់ឆន្ទានុសិទ្ធិរបស់ខ្លួន។ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យមុនពេលសវនាការ ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការយល់ឃើញស្របទៅនឹងសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយ អាចធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននៅពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ[14]។

10. មាត្រា ២០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
11. មាត្រា ២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
12. មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
13. មាត្រា ៣០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## ខ-តុលាការយោធា និងអយ្យការយោធា

### (១)-តុលាការយោធា

តុលាការយោធា គឺមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលើគ្រប់រឿងក្តីទូទាំងប្រទេស ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាយោធា[15] ដែលប្រព្រឹត្តដោយយោធិន។ បទល្មើសដែលមានលក្ខណៈយោធា (បទល្មើសយោធា) សំដៅដល់គ្រប់អំពើដែលធ្វើឱ្យប៉ះពាល់ដល់កម្លាំងប្រយុទ្ធរបស់កងកម្លាំងប្រដាប់អាវុធ បទបញ្ជាយោធា និងគ្រឿងអាវុធ និងគ្រឿងបរិក្ខាយោធា។ តុលាការយោធាដឹកនាំដោយប្រធាន ១រូប ព្រមទាំងអនុប្រធាន និងចៅក្រមមួយចំនួនជាជំនួយការ។ ប្រធាន អនុប្រធាន និងចៅក្រមតុលាការយោធា និងតំណាងអយ្យការយោធាត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ។ នៅពេលជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះ មានចៅក្រមម្នាក់ជាប្រធាន និងមានយោធិន ២ នាក់ជាទីប្រឹក្សា។ ទីប្រឹក្សាយោធា មានសិទ្ធិស្មើនឹងចៅក្រម។ ទីប្រឹក្សាយោធា ត្រូវបានជ្រើសរើសដោយអង្គការទទួលបន្ទុកកិច្ចការនយោបាយនៃកងទ័ព។ ក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការសម្រេចជាសមូហភាព និងតាមមតិភាគច្រើន។

### (២)-អយ្យការអមតុលាការយោធា

នៅអមតុលាការយោធា មានអយ្យការយោធា ដែលមានតួនាទីភារកិច្ចស៊ើបអង្កេត និងចោទប្រកាន់ជនល្មើសមានលក្ខណៈយោធានៅចំពោះមុខតុលាការយោធាកសាងសំណុំរឿងលើយោធិនទូទាំងកងយោធពលខេមរភូមិន្ទ ដែលមានបទល្មើសយោធា និងមានសិទ្ធិត្រួតពិនិត្យលើការជំនុំជម្រះរបស់តុលាការយោធា ព្រមទាំងធ្វើបណ្តឹងឧទ្ធរណ៍[16]។ តុលាការយោធា និងអយ្យការយោធាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ។ សេចក្តីសម្រេចរបស់តុលាការយោធា អាចត្រូវបានប្តឹងជំទាស់ទៅកាន់សាលាឧទ្ធរណ៍ភ្នំពេញ ហើយសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងនេះ អាចត្រូវបានប្តឹងសាទុក្ខទៅកាន់តុលាការកំពូល។

## ២.តុលាការជាន់ខ្ពស់

យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ទាប ចំណែកសាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្តីជាន់ខ្ពស់។

---

15. មាត្រា ១១ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការពារជាតិ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០
16. មាត្រា ១២ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការពារជាតិ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០

## ក-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

### (១)-សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ ជាសាលាជម្រះក្តីថ្នាក់ទី២ ដែលមានសមត្ថកិច្ចជំនុំជម្រះ និងសម្រេចសេចក្តី ទាំងអង្គហេតុ និងអង្គច្បាប់ លើរឿងក្តីដែលត្រូវបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់សាលាដំបូង និងសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកឱ្យជំនុំជម្រះឡើងវិញ។ សាលាឧទ្ធរណ៍ រួមមាន សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់។ ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់សមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ បច្ចុប្បន្ន សាលាឧទ្ធរណ៍តំបន់ ដែលត្រូវបានដាក់ឱ្យដំណើរការមានចំនួន៣ រួមមាន សាលាឧទ្ធរណ៍ព្រះសីហនុ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

**សាលាឧទ្ធរណ៍ភ្នំពេញ** មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែងនិងខេត្តស្វាយរៀង ព្រមទាំងរឿងក្តីផ្សេងទៀត ដែលមិនស្ថិត នៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍តំបន់[17]។

**សាលាឧទ្ធរណ៍ព្រះសីហនុ** មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប[18]។

**សាលាឧទ្ធរណ៍បាត់ដំបង** មានទីតាំងស្ថិតនៅក្នុងខេត្តបាត់ដំបង និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប[19] ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានទីតាំងស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី[20]។

សមាសភាពរបស់សាលាឧទ្ធរណ៍នីមួយៗរួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[21]។

---

17. មាត្រា ២ កថាខណ្ឌទី ៤ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
18. មាត្រា ២ កថាខណ្ឌទី ១ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
19. មាត្រា ២ កថាខណ្ឌទី ២ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
20. មាត្រា ២ កថាខណ្ឌទី ៣ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
21. មាត្រា ៣៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សាលាឧទ្ធរណ៍ មានសភាជំនាញ ដូចខាងក្រោម៖

- **សភាព្រហ្មទណ្ឌ** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- **សភារដ្ឋប្បវេណី** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្ត ជាធរមាន។
- **សភាស៊ើបសួរ** មានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- **សភាពាណិជ្ជកម្ម** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- **សភាការងារ** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីការងារ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតអាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។

សភានីមួយៗនៃសាលាឧទ្ធរណ៍ជំនុំជម្រះរឿងក្តី និងចេញសេចក្តីសម្រេចដោយមានចៅក្រម ៣ រូប ដែល ១រូបជាប្រធាន[22]។ ចំពោះរឿងក្តីដែលតុលាការកំពូលបានបង្វិលមកវិញ សាលាឧទ្ធរណ៍ ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយដោយមានចៅក្រម ៥ រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលជំនុំជម្រះលើកមុន[23]។

ចំពោះការជំនុំជម្រះរឿងក្តីនៅសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ ក្រៅពីចៅក្រម ៣ រូប ត្រូវមានអមដោយទីប្រឹក្សាពាណិជ្ជកម្ម២រូប ដែលមិនមែនជាទីប្រឹក្សាពាណិជ្ជកម្មនៅក្នុងរឿងក្តីតែមួយនៅសាលាដំបូង[24]។ ចំណែកការជំនុំជម្រះរឿងក្តីនៅសភាការងារនៃសាលាឧទ្ធរណ៍ ក្រៅពីចៅក្រម ៣ រូប ត្រូវមានអមដោយទីប្រឹក្សា ២ រូប ដែល ១ រូប ជាកម្មករនិយោជិត និង ១ រូបទៀត ជានិយោជក ហើយទីប្រឹក្សាទាំង ២រូបនេះ មិនមែនជាទីប្រឹក្សាការងារនៅក្នុងរឿងក្តីតែមួយនៅសាលាដំបូង[25]។

22. មាត្រា ៣៧ និងមាត្រា ៣៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
23. មាត្រា ៣៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
24. មាត្រា ៤៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
25. មាត្រា ៤៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សភារួមក្រុមអាចត្រូវបានបង្កើតឱ្យមានដំណើរការបានដោយដីកាសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ។ សភារួមក្រុមនេះអាចត្រូវបានបង្កើតឡើងក្នុងករណីដែលរឿងក្តីណាមួយចោទជាបញ្ហាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើនឬក្នុងករណីដែលបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នានៅចំពោះមុខសភាផ្សេង គ្នានៃសាលាឧទ្ធរណ៍តែមួយ។ សភារួមក្រុម ត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ៥រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ។សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍និងត្រូវដំណើរការក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍។ សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទច្បាប់ មានអំណាចបង្ខំឱ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម។សេចក្តីសម្រេចរបស់សភារួមក្រុមលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

### (២)-មហាអយ្យការអមសាលាឧទ្ធរណ៍

នៅតាមសាលាឧទ្ធរណ៍នីមួយៗ មានមហាអយ្យការអមសាលាឧទ្ធរណ៍ ដែលមានសមាសភាពដូចតទៅៈ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[26]។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយមានសិទ្ធិអំណាចចាត់តាំង និងបែងចែកការងារដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់នៅក្នុងសាលាឧទ្ធរណ៍របស់ខ្លួន។ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជ អាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ពិនិត្យមុនពេលសវនាការ ប៉ុន្តែនាពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របទៅនឹងសតិសម្បជញ្ញៈរបស់ខ្លួន។គ្មានការចោទប្រកាន់ខាងវិន័យណាមួយអាចត្រូវធ្វើចំពោះតំណាងមហា អយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ[27]។

ក្រៅពីសិទ្ធិអំណាចគ្រប់គ្រងទៅលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក៏មានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូងដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនធ្វើការចោទប្រកាន់ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[28]។

---

26. មាត្រា ៤៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
27. មាត្រា ៥១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
28. មាត្រា ៥១ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## ខ-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

### (១)-តុលាការកំពូល

តុលាការកំពូលជាសាលាជម្រះក្តីថ្នាក់ខ្ពស់បំផុត។តុលាការកំពូលមានតែមួយគត់ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីនៃប្រទេសកម្ពុជាទាំងមូល។ តុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ឬចំពោះសាលក្រមសាលាដំបូងនៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរមិនប្តឹងឧទ្ធរណ៍ឬនៅក្នុងករណីដែលសាលក្រមសាលាដំបូងវិនិច្ឆ័យលើរឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនលើសពី៥លានរៀល[29]។សមាសភាពរបស់តុលាការកំពូលរួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[30]។

តុលាការកំពូល ត្រូវបែងចែកជា សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និងសភាការងារ។ ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតរបស់តុលាការកំពូល អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។ សភានីមួយៗ ចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងនាមតុលាការកំពូល។ ចំពោះបណ្តឹងសាទុក្ខលើកទី១ សភានីមួយៗនៃតុលាការកំពូលជំនុំជម្រះនឹងចេញសេចក្តីសម្រេចដោយមានចៅក្រម៥រូប ដែល១រូបជាប្រធាន[31]ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន។ ចំពោះបណ្តឹងសាទុក្ខលើកទី១ តុលាការកំពូលជំនុំជម្រះ នឹងសម្រេចសេចក្តីទៅលើអង្គច្បាប់តែប៉ុណ្ណោះ។ ក្នុងការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី ១ នេះ, តុលាការកំពូល អាចសម្រេចតម្កល់ឬបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ហើយសម្រេចសេចក្តីតែម្តង ក្នុងករណីដែលតុលាការកំពូលយល់ថា សាលាឧទ្ធរណ៍បានកំណត់ចំណុចវិវាទច្បាស់លាស់ និងបានវិនិច្ឆ័យអំពីអង្គហេតុច្បាស់លាស់ហើយ។ ដោយឡែក ក្នុងករណីដែលពិនិត្យឃើញថា សាលាឧទ្ធរណ៍នៅមិនទាន់បានវិនិច្ឆ័យច្បាស់លាស់អំពីចំណុចវិវាទ ឬអំពីអង្គហេតុ,តុលាការកំពូលអាចសម្រេចបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍និងបង្វិលសំណុំរឿងឱ្យទៅសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញ។

ចំពោះបណ្តឹងសាទុក្ខលើកទី២ បណ្តឹងសើរើ ឬបណ្តឹងសុំជំនុំជម្រះសាជាថ្មីឡើងវិញចំពោះសាលក្រម និងសាលដីកាស្ថាពរ តុលាការកំពូលជំនុំជម្រះ នឹងចេញសេចក្តីសម្រេចដោយសភាពេញអង្គ ដែលមានសមាសភាពចៅក្រមយ៉ាងតិច៩រូប ដែលមានចៅក្រមជាតំណាងនៃ

29. មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី
30. មាត្រា ៥៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
31. មាត្រា ៥៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សភាទាំងអស់របស់តុលាការកំពូល ហើយត្រូវដំណើរការក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល[32]។ ករណីនេះ តុលាការកំពូលជំនុំជម្រះ នឹងសម្រេចសេចក្តីទាំងអង្គហេតុ និងអង្គច្បាប់។ ដោយឡែកតុលាការកំពូលក៏អាចបង្កើតជាសភារួមក្រុម ដោយសេចក្តីសម្រេចរបស់ប្រធានតុលាការកំពូល តាមគំនិតផ្តួចផ្តើមរបស់ប្រធានតុលាការកំពូល ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើនឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នានៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូល។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល។ សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទអំពីច្បាប់ មានអំណាចបង្ខំសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

### (២)-មហាអយ្យការអមតុលាការកំពូល

នៅអមតុលាការកំពូល មានមហាអយ្យការមួយ ដែលមានសមាសភាពដូចតទៅ៖ អគ្គព្រះរាជ-អាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[33]។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចចាត់តាំង និងបែងចែកការងារដល់អគ្គព្រះរាជ-អាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់នៅមហាអយ្យការអមតុលាការកំពូល។ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលពិនិត្យមុនពេលសវនាការ ប៉ុន្តែនាពេលសវនាការអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របទៅនឹងសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយ អាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ[34]។

## ៣. អង្គភាពរដ្ឋបាលតុលាការ

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ បានបង្កើតឱ្យមានអង្គភាពរដ្ឋបាលតុលាការមួយនៅតាមគ្រប់សាលាជម្រះក្តីនានា ទាំងសាលាដំបូងរាជធានី-ខេត្ត ទាំងសាលាឧទ្ធរណ៍

32. មាត្រា ៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
33. មាត្រា ៦៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
34. មាត្រា ៥១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

និងទាំងតុលាការកំពូល។ អង្គភាពរដ្ឋបាលតុលាការ គឺជាអង្គភាពថ្មីស្រឡាងមួយ ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិច្បាប់ខ្មែរ ហើយការបង្កើតអង្គភាពរដ្ឋបាលតុលាការនេះគឺជាសមិទ្ធផលដ៏ចម្បងមួយនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃសេវាយុត្តិធម៌។ អង្គភាពរដ្ឋបាលតុលាការនេះ ជាសេនាធិការឱ្យសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី លើការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ការងារទំនាក់ទំនងសាធារណៈ និងការងារគ្រប់គងរដ្ឋបាលតុលាការ ជាអាទិ៍ ការងារទទួលពាក្យបណ្តឹង និងការគ្រប់គ្រងសំណុំរឿង និងវឌ្ឍនភាពនៃពាក្យបណ្តឹង និងការងារផ្សេងទៀតតាមការកំណត់របស់លិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គភាពរដ្ឋបាលតុលាការនេះបានជួយសម្រាលបន្ទុកការងាររបស់ក្រឡាបញ្ជីនិងរបស់ប្រធានសាលាជម្រះក្តីនីមួយៗដោយអនុញ្ញាតឱ្យចៅក្រមព្រះរាជអាជ្ញានិងក្រឡាបញ្ជីផ្តោតការយកចិត្តទុកដាក់ខ្ពស់តែលើការងារបច្ចេកទេសសំណុំរឿងសំដៅធ្វើយ៉ាងណាឱ្យការជំនុំជម្រះក្តីអាចធ្វើឡើងបានលឿនត្រឹមត្រូវនិងយុត្តិធម៌ស្របតាមច្បាប់និងនីតិវិធីជាធរមាន។វត្តមានរបស់អង្គភាពរដ្ឋបាលតុលាការក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការៈ(១)-ពន្លឿនការដោះស្រាយសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី, (២)-លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ ដែលមានលក្ខណៈងាយស្រួលប្រើ និងឆាប់រហ័ស ដោយសារអង្គភាពរដ្ឋបាលតុលាការនេះ បានក្លាយជាច្រកចេញ-ចូលតែមួយសម្រាប់ប្រជាពលរដ្ឋដាក់ពាក្យបណ្តឹង និងទទួលបាននូវព័ត៌មានអំពីវឌ្ឍនភាពនៃចំណាត់ការលើពាក្យបណ្តឹងរបស់ខ្លួន, (៣)-លើកកម្ពស់ប្រសិទ្ធភាពនៃការចុះបញ្ជី និងការគ្រប់គ្រងសំណុំរឿង និង (៤)-លើកកម្ពស់ប្រសិទ្ធភាពនៃការងារនាំពាក្យ និងទំនាក់ទំនងសាធារណៈ។

អង្គភាពរដ្ឋបាលតុលាការ ត្រូវបានបែងចែកជា **លេខាធិការដ្ឋានរដ្ឋបាលតុលាការ** សម្រាប់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត និង **អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការ** សម្រាប់សាលាឧទ្ធរណ៍និងតុលាការកំពូល។ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពរដ្ឋបាល តុលាការ ត្រូវកំណត់ដោយអនុក្រឹត្យ។ អង្គភាពរដ្ឋបាលតុលាការ ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ហើយមន្ត្រីរបស់អង្គភាពរដ្ឋបាលតុលាការ គឺជាមន្ត្រីក្របខ័ណ្ឌរបស់ក្រសួងយុត្តិធម៌។ ផ្អែកតាមច្បាប់ ក្រសួងយុត្តិធម៌ មានសិទ្ធិត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់។ក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញលិខិតបទដ្ឋានគតិយុត្តនិងសេចក្តីណែនាំនានាដើម្បីធានាដំណើរការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់។ ក្រសួងយុត្តិធម៌ គ្រប់គ្រងតែលើការងាររដ្ឋបាលតុលាការប៉ុណ្ណោះ ដោយឡែកការជំនុំជម្រះនិងការសម្រេចសេចក្តីគឺសិទ្ធិសម្រេចស្វ័យភាពនិងដោយឯករាជ្យរបស់ចៅក្រម៕